# **សុន្ទរកថាស្វាគមន៍**
# **របស់ អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**
# **ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
# **និង ជាប្រធានគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ**
# **ថ្លែងនៅក្នុង**
# **ពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ ប្រព័ន្ធបញ្ជរតែមួយជាតិ**

*រាជធានីភ្នំពេញ, ថ្ងៃទី ៧ ខែ ឧសភា គ.ស. ២០២៤*

- **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត;*
- *ឯកឧត្តម, លោកជំទាវ, សមាជិក-សមាជិកា នៃរាជរដ្ឋាភិបាល;*
- *ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី, ជាទីមេត្រី!*

ជាកិច្ចចាប់ផ្តើម, ក្នុងនាមជាប្រធានគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ, ខ្ញុំសូមគោរពសម្តែងនូវអំណរគុណដ៏ជ្រាលជ្រៅបំផុត ជូនចំពោះ **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** ដែលបានផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ អញ្ជើញជាអធិបតី ក្នុង **ពិធីប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ ប្រព័ន្ធបញ្ជរតែមួយជាតិ** ដែលជាសមិទ្ធផលថ្មីមួយទៀតរបស់រាជរដ្ឋាភិបាល ក្នុងកិច្ចប្រឹងប្រែងធ្វើឱ្យប្រសើរឡើង នូវបរិយាកាសធុរកិច្ច, ជំរុញការធ្វើពាណិជ្ជកម្ម និង លើកកម្ពស់កំណើនសេដ្ឋកិច្ច នៅកម្ពុជា ។

ដោយទទួលស្គាល់នូវសារៈសំខាន់នៃបច្ចេកវិទ្យាឌីជីថល, កម្ពុជា ត្រូវបានមើលឃើញយ៉ាងច្បាស់ថា កំពុងស្ថិតក្នុងដំណើរយ៉ាងសកម្មនៃការធ្វើបរិវត្តកម្មឌីជីថល លើគ្រប់ទិដ្ឋភាព និង គ្រប់តួអង្គ, ទាំងរដ្ឋ, ឯកជន, និង ប្រជាពលរដ្ឋ ។ ដើម្បីទាញយកប្រយោជន៍ជាអតិបរមា

ពីបច្ចេកវិទ្យាឌីជីថល, រាជរដ្ឋាភិបាល នីតិកាលទី ៦ នៃរដ្ឋសភា បានប្រកាសដាក់ឱ្យអនុវត្ត នូវ «**ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥**» នៅឆ្នាំ ២០២១ ។ លើមូលដ្ឋាននេះ, រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា ក៏បានប្រកាសដាក់ឱ្យអនុវត្ត នូវ «**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១**» ដោយក្នុងនោះ «**បច្ចេក-វិទ្យា**», ពិសេស **បច្ចេកវិទ្យាឌីជីថល**, ត្រូវបានកំណត់ជាអាទិភាពគន្លឹះថ្មីមួយទៀត, បន្ថែមពីលើអាទិភាពគន្លឹះទាំង ៤ នៃ **យុទ្ធសាស្ត្រចតុកោណ** ពោលគឺ ៖ **មនុស្ស, ផ្លូវ, ទឹក និង ភ្លើង** ។ អាទិ-ភាពគន្លឹះថ្មីនេះ ត្រូវបានយកមករៀបចំជាវិធានការយុទ្ធសាស្ត្រសម្រាប់ការអនុវត្តជាក់ស្តែង នៅក្នុង **បញ្ចកោណទី ៥** នៃ «**យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១**» គឺ បញ្ចកោណស្តីពី «**ការកសាងសេដ្ឋកិច្ច និង សង្គមឌីជីថល**» ។

ជាការចូលរួមចំណែកក្នុងកិច្ចការនេះ, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានចាប់ផ្តើមធ្វើទំនើបកម្មការងារ និង មុខងាររបស់ខ្លួន ជាបណ្តើរៗ ក្នុងរយៈពេលជាង ១០ ឆ្នាំចុងក្រោយ ដោយផ្តោតអាទិភាពលើការងារស្នូលរបស់ខ្លួន ជាអាទិ៍ ការគ្រប់គ្រងថវិកា និង ការគ្រប់គ្រងចំណូល ។ នៅក្នុងផ្នែកថវិកា និង រតនាគារ, ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ត្រូវបានអភិវឌ្ឍ និង ដាក់ឱ្យអនុវត្ត ជាដំណាក់កាល ។ នៅក្នុងផ្នែកចំណូល, អគ្គ-នាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា, អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និង ចំណូលមិនមែនសារពើពន្ធ បាន និង កំពុងបន្តជំរុញ ធ្វើទំនើបកម្មការងារ ដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល តាមរយៈការដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធបច្ចេកវិទ្យាជាច្រើន នាពេលកន្លងមក ដែលខ្ញុំមិនអាចរៀបរាប់អស់ នៅពេលនេះ ។ ក្រៅពីប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ដែលគាំទ្រដល់មុខងារបច្ចេកទេសនីមួយៗ, ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានគិតគូរលើការរៀបចំជាប្រព័ន្ធអេកូឡូស៊ីនៃថ្នាលបច្ចេកវិទ្យា ដែលមានភាពប្រទាក់ក្រឡាគ្នា ដោយអនុញ្ញាតឱ្យប្រព័ន្ធបច្ចេកវិទ្យា-ព័ត៌មានផ្សេងៗ, ទាំងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានក្នុងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួង-ស្ថាប័នផ្សេងទៀតនៃរាជរដ្ឋាភិបាល អាចធ្វើការប្រទាក់ក្រឡាជាមួយគ្នាបាន ជាចង្កោមនៃអង្គតែមួយ ។ ការដាក់ចេញនូវថ្នាលឌីជីថលគន្លឹះ សំខាន់ៗ ដូចជា **ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា** (CamDX) បានបើកឡើងនូវឱកាសឱ្យប្រព័ន្ធដទៃទៀត អាចធ្វើ-ការរួមគ្នា និង ប្រទាក់ក្រឡាគ្នា ដោយបង្កើតបានជាសេវាឌីជីថលថ្មីៗ ដែលកាន់តែងាយស្រួល និង មានប្រសិទ្ធភាព ជាងមុន ។ ជាក់ស្តែង, ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យា-

ព័ត៌មាន ដែលតភ្ជាប់ជាខ្សែច្រវាក់ពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយ ទៅប្រព័ន្ធបច្ចេកវិទ្យា-ព័ត៌មានមួយទៀត នៃក្រសួង-ស្ថាប័ន ចំនួន ២១ បានអនុញ្ញាតឱ្យធុរជន ចុះបញ្ជីអាជីវកម្ម ដោយប្រើពេល ត្រឹមតែ ៨ ថ្ងៃ នៃថ្ងៃធ្វើការប៉ុណ្ណោះ ។ បើគិតពីពេលចាប់ផ្តើមដាក់ឱ្យដំណើការ CamDX នៅពាក់កណ្តាលឆ្នាំ ២០២០ មកដល់ដំណាច់ខែ មេសា ឆ្នាំ ២០២៤ នេះ, ក្រុម-ហ៊ុន ចំនួន ៣៥ ៧៥៥, ជាមួយនឹងទំហំដើមទុន ១០,៧៣ ប៊ីលានដុល្លារអាមេរិក, បានចុះបញ្ជីដោយជោគជ័យ ក្នុងប្រព័ន្ធអេកូឡូស៊ីនេះ ។

- *សម្តេចធិបតី ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត;*
- *អង្គពិធីទាំងមូល ជាទីមេត្រី!*

ពេលនេះ, ការងារធ្វើទំនើបកម្មដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល នៅតាមអង្គភាពនានា នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បាន និង កំពុង ក្លាយជាការងារប្រចាំថ្ងៃ ។ ប្រព័ន្ធបញ្ចូរតែមួយជាតិ គឺជាប្រព័ន្ធថ្មីមួយទៀត របស់អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា ដែលបំពេញបន្ថែម និង ធ្វើការជាមួយនឹងប្រព័ន្ធដែលមានស្រាប់ ដូចជា E-customs, ASYCUDA, Pre-Arrival Manifest System ជាដើម ។ ប្រព័ន្ធបញ្ចូរតែមួយជាតិនេះ នឹងអនុញ្ញាតឱ្យអ្នកនាំចេញ-នាំចូលទំនិញ អាចដាក់ស្នើសុំ អាជ្ញាបណ្ណ, លិខិតអនុញ្ញាត, វិញ្ញាបនបត្រ, និង ឯក-សារតម្រូវផ្សេងទៀត ពាក់ព័ន្ធនឹងការនាំចេញ-នាំចូលទំនិញ, ទៅគ្រប់ក្រសួង-ស្ថាប័នមានសមត្ថកិច្ច តែមួយលើករួមគ្នា ដើម្បីទទួលបាននូវការអនុញ្ញាត សម្រាប់យកទៅប្រើប្រាស់ ក្នុងការបំពេញបែបបទបញ្ចេញទំនិញពីគយ តាមមធ្យោបាយអេឡិចត្រូនិក ។ ទន្ទឹមនេះ, ប្រព័ន្ធបញ្ចូរតែមួយជាតិ ក៏មានមុខងារដ៏សំខាន់ ក្នុងការតភ្ជាប់ទៅកាន់ប្រព័ន្ធបញ្ចូរតែមួយអាស៊ាន ដើម្បីផ្លាស់ប្តូរទិន្នន័យវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ, ទិន្នន័យឯកសារប្រតិវេទន៍គយ និង ទិន្នន័យឯកសារពាណិជ្ជកម្មផ្សេងទៀត តាមទម្រង់អេឡិចត្រូនិក ជាមួយនឹងបណ្តាប្រទេសជាសមាជិកអាស៊ាន ផងដែរ ។

អនុវត្តតាមយុទ្ធសាស្ត្រ និង គោលនយោបាយ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីកិច្ច-សម្រួលពាណិជ្ជកម្ម និង អនុលោមតាមកិច្ចព្រមព្រៀងស្តីពីការបង្កើត និង ការអនុវត្តបញ្ចូរតែមួយអាស៊ាន និង កិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម របស់អង្គការពាណិជ្ជកម្មពិភពលោក ដែលកម្ពុជាបានអនុម័តយល់ព្រមជាបន្តបន្ទាប់ ក្នុងពេលកន្លងទៅ, រាជរដ្ឋាភិ-

បាល បានសម្រេចបង្កើតគណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិឡើង នាខែ មីនា ឆ្នាំ ២០១៥, ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង មានតំណាងនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ ព្រមទាំងតំណាងនៃវិស័យឯកជន ជាសមាជិក ហើយមានលេខាធិការដ្ឋាននៅអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា ដែលមានតួនាទីសម្របសម្រួលការអភិវឌ្ឍ និង ការ-អនុវត្តគម្រោង ។

គម្រោងបញ្ជរតែមួយជាតិ ត្រូវបានចែកចេញជា ៣ ដំណាក់កាល ដោយប្រើប្រាស់ថវិកាសរុប ក្នុងរយៈពេល ៧ ឆ្នាំ, ពោលគឺ ពី ២០១៨ ដល់ ២០២៤, ប្រមាណ ៣,៤ លានដុល្លារអាម៉េរិក ។

**ការអភិវឌ្ឍដំណាក់កាលទី ១** បានផ្តោតជាសំខាន់ទៅលើការរៀបចំថ្នាលបច្ចេកវិទ្យា-ព័ត៌មាន សម្រាប់តភ្ជាប់រវាងប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ (អាសុីគូដា) ជាមួយនឹងប្រព័ន្ធស្វ័យប្រវត្តិកម្មវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញរបស់ក្រសួងពាណិជ្ជកម្ម និង សម្រាប់តភ្ជាប់ទៅប្រព័ន្ធបញ្ជរតែមួយអាស៊ាន ។

**ដំណាក់កាលទី ២** បានពង្រីកបន្ថែមមុខងារថ្នាលបច្ចេកវិទ្យាព័ត៌មាន ឱ្យមានវិសាលភាពបន្ថែម ទៅលើក្រសួង-ស្ថាប័ន ដែលមានប្រតិបត្តិការច្រើន ក្នុងការចេញ អាជ្ញាបណ្ណ, លិខិតអនុញ្ញាត, ព្រមទាំងវិញ្ញាបនបត្រ និង ឯកសារផ្សេងៗ, ក្នុងនោះមាន អគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា, ក្រសួងពាណិជ្ជកម្ម, ក្រសួងសុខាភិបាល, ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និង នវានុវត្តន៍, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ។

**ដំណាក់កាលទី ៣** បានពង្រីកវិសាលភាពបន្ថែម ឱ្យគ្របដណ្តប់គ្រប់ក្រសួង-ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនឹងការចេញ អាជ្ញាបណ្ណ, លិខិតអនុញ្ញាត, វិញ្ញាបនបត្រ, និង ឯកសារផ្សេងៗ សម្រាប់ទំនិញនាំចេញ-នាំចូល ស្របតាមខ្លឹមសារនៃអនុក្រឹត្យស្តីពីការដាក់ឱ្យប្រើ-ប្រាស់បញ្ជីទំនិញហាមឃាត់ និង ទំនិញជាប់កម្រិតកំណត់; និង សម្រាប់ទំនិញដែលទទួលបាននូវការលើកទឹកចិត្តពន្ធ និង អាករ តាមច្បាប់ និង បទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន ។ ក្រសួង-ស្ថាប័នទាំងនេះ រួមមាន ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, ក្រសួងមហាផ្ទៃ, ក្រសួងការពារជាតិ, ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ, ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ, ក្រសួងបរិស្ថាន, ក្រសួងរ៉ែ និង ថាមពល, ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍, និង ធនាគារជាតិនៃកម្ពុជា ។

- *សម្តេចធិបតី ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត;*
- *អង្គពិធីទាំងមូលជាទីមេត្រី !*

ការដាក់ឱ្យអនុវត្តប្រព័ន្ធបញ្ជរតែមួយជាតិ នឹងនាំមកនូវផលប្រយោជន៍ជាច្រើន, ទាំងសម្រាប់វិស័យសាធារណៈ និង វិស័យឯកជន ។ សម្រាប់វិស័យសាធារណៈ, ប្រព័ន្ធបញ្ជរតែមួយជាតិ មានតួនាទីសំខាន់ ក្នុងការសម្របសម្រួល និង ការពង្រឹងកិច្ចសហការ រវាងក្រសួង-ស្ថាប័នជំនាញពាក់ព័ន្ធ សំដៅបង្កើនប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាពបន្ថែមទៀត នូវកិច្ចសម្រួលពាណិជ្ជកម្ម, ជាពិសេស សម្រួលដល់ការបំពេញឱ្យបានឆាប់ នូវបែបបទនាំចេញ-នាំចូលទំនិញ ស្របតាមយុទ្ធសាស្ត្រ និង គោលនយោបាយរបស់រាជរដ្ឋាភិបាល ។ ជារួម, ប្រព័ន្ធនេះ បានផ្តល់អត្ថប្រយោជន៍សំខាន់ដល់ក្រសួង-ស្ថាប័នជំនាញពាក់ព័ន្ធ ឱ្យទទួលបាននូវ ព័ត៌មាន និង ទិន្នន័យ ត្រឹមត្រូវ និង ទាន់ពេល សម្រាប់ធ្វើការវិភាគវាយតម្លៃហានិភ័យ និង សម្រាប់ប្រើប្រាស់តាមតម្រូវការផ្សេងទៀត ។

ដោយឡែក, វិស័យឯកជន ក៏នឹងទទួលបានអត្ថប្រយោជន៍ជាច្រើនផងដែរ ដូចជា ចំណេញពេល; ព្រមទាំងការកាត់បន្ថយចំណាយ; និង ជាពិសេស, ការកាត់បន្ថយការិយាធិបតេយ្យ ក្នុងការរត់ការឆ្លងកាត់ពីក្រសួង-ស្ថាប័នមានសមត្ថកិច្ចមួយ ទៅមួយទៀត ពាក់ព័ន្ធនឹងការស្នើសុំអាជ្ញាបណ្ណ, លិខិតអនុញ្ញាត, វិញ្ញាបនបត្រ, និង ឯកសារតម្រូវផ្សេងៗ, សម្រាប់ការនាំចេញ-នាំចូលទំនិញ ។ លើសពីនេះ, ប្រតិបត្តិករនៃវិស័យឯកជន ក៏អាចប្រើប្រាស់ឡើងវិញ នូវទិន្នន័យក្នុងប្រព័ន្ធ សម្រាប់ជាប្រយោជន៍ក្នុងការគ្រប់គ្រងទិន្នន័យរបស់ខ្លួន ឱ្យបានទាន់ពេល, មានសង្គតិភាព និង មានភាពច្បាស់លាស់ ផងដែរ ។

- *សម្តេចធិបតី ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត;*
- *អង្គពិធីទាំងមូលជាទីមេត្រី !*

មុននឹងបញ្ចប់, ក្នុងនាម **គណៈកម្មាធិការដឹកនាំគម្រោងបញ្ជរតែមួយជាតិ** ក៏ដូចជា **ក្រុម-ការងារគណៈកម្មាធិការជាតិកិច្ចសម្រួលពាណិជ្ជកម្ម**, យើងខ្ញុំទាំងអស់គ្នា សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ជូន **សម្តេចតេជោ ប្រធានព្រឹទ្ធសភា និង ជាអតីតនាយករដ្ឋមន្ត្រី, និង សម្តេចធិបតី នាយករដ្ឋមន្ត្រី** សម្រាប់ការផ្តល់នូវការណែនាំ

និង អនុសាសន៍ល្អៗ ដែលអនុញ្ញាតឱ្យការរៀបចំ **គម្រោងបញ្ជរតែមួយជាតិ** ទទួលបានជោគ-ជ័យ ដែលនឹងត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នាពេលបន្តិចទៀតនេះ ។

ឆ្លៀតក្នុងឱកាសនេះ, ខ្ញុំក៏សូមអំពាវនាវដល់គ្រប់ក្រសួង-ស្ថាប័ន និង វិស័យឯកជន សូមចូលរួមអនុវត្ត និង ប្រើប្រាស់ប្រព័ន្ធបញ្ជរតែមួយជាតិនេះ ឱ្យបានប្រកបដោយប្រសិទ្ធភាព ជាអតិបរមា ។

នៅចុងបញ្ចប់, ខ្ញុំសូមគោរពជូនពរ **សម្តេចធិបតី នាយករដ្ឋមន្ត្រី** និង អង្គពិធីទាំងមូល បានសមប្រកបនឹងពុទ្ធពរទាំងបួនប្រការ គឺ៖ **អាយុ, វណ្ណៈ, សុខៈ, និង ពលៈ,** ព្រមទាំងពរមួយប្រការទៀត គឺ **បដិភាណៈ**, កុំបីឃ្លៀងឃ្លាតឡើយ ៕

*សូមអរគុណ !*